អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
អគ្គនាយកដ្ឋានស្រាវជ្រាវ
នាយកដ្ឋានស្រាវជ្រាវថវិកា

# ព្រឹត្តិបត្រព័ត៌មានថវិកា និងសេដ្ឋកិច្ច

## មាតិកា៖

- រាជរដ្ឋាភិបាលគ្រោងបង្កើនការចំណាយជាង ៨% និងបង្កើនចំណូលជាង ១៩% នៅឆ្នាំ២០២២
- រាជរដ្ឋាភិបាលដាក់ចេញគោលការណ៍គន្លឹះ៥ចំណុចក្នុងការខ្ចី និងគ្រប់គ្រងបំណុល
- រាជរដ្ឋាភិបាលកម្ពុជា គ្រោងធ្វើការបោះផ្សាយលក់នូវមូលបត្ររដ្ឋ៣០០លានដុល្លារនៅ ឆ្នាំក្រោយ
- ក្រុមអ្នកវិនិយោគចិន កំពុងសិក្សាឱកាសវិនិយោគលើការកែច្នៃត្រី ក្នុងខេត្តកំពង់ឆ្នាំង
- ការនាំចេញរ៉ែមាសកម្ពុជាផ្តល់ចំណូលចូលរដ្ឋជាង៦៦ម៉ឺនដុល្លារ ក្រោយដំណើរការបាន៤ខែ
- ផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តសៀមរាប នឹងផ្តល់ផ្លែផ្កាអ្វីខ្លះដល់សេដ្ឋកិច្ចកម្ពុជា?
- ពាណិជ្ជកម្មទ្វេភាគីកម្ពុជា និងជប៉ុនបានកើនដល់១,៥ប៊ីលានដុល្លារអាមេរិក គិតត្រឹម៨ខែ ឆ្នាំ២០២១
- អតិរេកពាណិជ្ជកម្មរបស់ឥណ្ឌូនេស៊ី សម្រាប់ខែកញ្ញា ឆ្នាំ២០២១ (គិតជាពាន់លានដុល្លារ)
- ពាណិជ្ជកម្មអន្តរជាតិវៀតណាម សម្រាប់រយៈពេល ០៨ ខែដំបូង នៃឆ្នាំ២០២១ (គិតជាពាន់លានដុល្លារ)
- សេដ្ឋកិច្ចកូរ៉េខាងត្បូង មានកំណើនយឺតជាងការរំពឹងទុកនៅក្នុងត្រីមាសទី៣ ឆ្នាំ២០២១
- ប្រទេសឥណ្ឌូនេស៊ី មើលឃើញកំណើនផ.ស.ស. របស់ខ្លួនក្នុងអត្រា ៤,៥% នៅត្រីមាសទី៣ ឆ្នាំ២០២១
- ចក្រភពអង់គ្លេសនឹងដំឡើងប្រាក់ឈ្នួលអប្បបរមាដល់ ៩.៥០ ផោនក្នុងមួយម៉ោង
- ព្រឹទ្ធសភាគណបក្សប្រជាធិបតេយ្យជំរុញឱ្យយកពន្ធលើមហាសេដ្ឋីដើម្បីជួយដល់ផែនការចំណាយ
- សេដ្ឋកិច្ចកើនយឺតជំរុញឱ្យចិននឹងពន្លឿនការបោះផ្សាយមូលបត្ររដ្ឋក្នុងស្រុក ២២៤ ពាន់លានដុល្លារបន្ថែម


ពិនិត្យ និងកែសម្រួលដោយ

- សួន ពុធថាវី	អគ្គនាយិកា នៃអគ្គនាយកដ្ឋានស្រាវជ្រាវ
- គីម សុចិត្រា	អគ្គនាយករង នៃអគ្គនាយកដ្ឋានស្រាវជ្រាវ
- ណុប ចាន់ធី	ប្រធាននាយកដ្ឋានស្រាវជ្រាវថវិកា
- ម៉ែន ខែមវៈ	អនុប្រធាននាយកដ្ឋានស្រាវជ្រាវថវិកា



រៀបរៀងដោយនាយកដ្ឋានស្រាវជ្រាវថវិកា	សប្តាហ៍ទី១ ខែវិច្ឆិកា ឆ្នាំ២០២១	លេខ ៖ ៩១

## ព័ត៌មាន និងទិន្នន័យអំពីប្រទេសកម្ពុជា

### រាជរដ្ឋាភិបាលគ្រោងបង្កើនការចំណាយជាង ៨% និងបង្កើនចំណូលជាង ១៩% នៅឆ្នាំ២០២២



*(រូបថតដោយ ប៊ុក ន្ធោ/ខេមបូណ្ឌមីស)ផ្លូវក្រវាត់ក្រុងខ្សែទី៣*

គម្រោងថវិកាជាតិឆ្នាំ២០២២ ត្រូវបានរាជរដ្ឋាភិបាលដំឡើងការចំណាយជាង៨%បន្ថែមទៀត រីឯចំណូលក៏ត្រូវបានដំឡើងជាង១៩% បើធៀបនឹងថវិកាជាតិឆ្នាំ២០២១។ ក្នុងនោះ គម្រោងចំណាយថវិកាជាតិ មានចំនួនជាង៣៤ទ្រីលានរៀលស្មើប្រមាណជាង ៨ ៥០០ លានដុល្លារ ប្រហែលជិត២៨%នៃផ.ស.ស រីឯចំណូលថវិកាជាតិត្រូវបានគ្រោងជាង២៥ទ្រីលានរៀល ស្មើនឹងប្រមណា ៦ ៣០០ លានដុល្លារអាមេរិក ឬស្មើនឹង២០% នៃ ផ.ស.ស។

ថវិកាជាតិឆ្នាំ២០២២ ត្រូវបានគិតគូរ និងរៀបចំឡើងក្នុងបរិការណ៍ដែលកម្ពុជា ក៏ដូចជាពិភពលោក ទាំងមូលកំពុងស្ថិតនៅក្នុងវិបត្តិជំងឺកូវីដ-១៩នៅឡើយ ដែលតម្រូវឱ្យរាជរដ្ឋាភិបាលតម្រង់ការប្រើប្រាស់ធនធានដើម្បីទ្រទ្រង់ដល់កិច្ចខិតខំប្រយុទ្ធនឹងជំងឺកូវីដ-១៩ និងស្តារ/ជំរុញសេដ្ឋកិច្ចឱ្យបន្តស្ថិតនៅលើគន្លង នៃកំណើនខ្ពស់ និងរស់រវើកឡើងវិញ ព្រមទាំងស្តារជីវភាពរបស់ប្រជាជនទូទៅ ក៏ដូចជាដើម្បីសម្រេចឱ្យបាននូវគោលដៅសំខាន់ៗ នៃកម្មវិធីនយោបាយយុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៤ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០១៩-២០២៣។

ជាលទ្ធផលអតិរេកថវិកាចរន្ត អាចរក្សាបានក្នុងកម្រិតប្រមាណជិត៣% នៃផ.ស.ស នៅឆ្នាំ២០២២ និងមានឱនភាពថវិកាសរុបស្មើនឹងជាង (-៧%) នៃផ.ស.ស។ ដើម្បីបំពេញបន្ថែម ឱនភាពថវិកានេះ រដ្ឋាភិបាលនឹងបន្តស្វែងរកហិរញ្ញប្បទានក្រៅប្រទេស ក្នុងទំហំជិត៥% នៃផ.ស.ស បន្ថែមទៀត រួមទាំងប្រភពហិរញ្ញវត្ថុពីមូលនិធិទ្រទ្រង់ថវិកាទំហំជាង១%នៃផ.ស.ស និងប្រាក់បញ្ញើរដ្ឋាភិបាលប្រមាណ៥០០លានដុល្លារ ផងដែរ។ ប្រភពហិរញ្ញវត្ថុបន្ថែមទៀតនោះ ដែលរដ្ឋាភិបាលទាញយកមកបង្គ្រប់ការចំណាយនៅឆ្នាំក្រោយនេះ គឺរាជរដ្ឋាភិបាល នឹងធ្វើការបោះផ្សាយលក់មូលបត្ររដ្ឋជាលើកដំបូងក្នុងទំហំប្រមាណ៣០០លានដុល្លារអាមេរិកផងដែរ។

នៅឆ្នាំ២០២២ខាងមុខ រាជរដ្ឋាភិបាលកម្ពុជារំពឹងថាកំណើនសេដ្ឋកិច្ចកម្ពុជានឹងកើនក្នុងរង្វង់៤,៨% ដែលធ្វើឱ្យផលិតផលក្នុងស្រុកសរុប មានក្នុងទំហំជាង៣០ ០០០លានដុល្លារអាមេរិក ហើយផលិតផលក្នុងស្រុកសរុបសម្រាប់មនុស្សម្នាក់វិញត្រូវបានរំពឹងថានឹងកើនដល់ ១ ៨៤២ ដុល្លារអាមេរិក កើនពី១ ៧៣០ដុល្លារអាមេរិកកាលពីឆ្នាំ២០២១។ គម្រោងថវិកាជាតិឆ្នាំ២០២២ ត្រូវបានគណៈរដ្ឋមន្ត្រីអនុម័តទាំងស្រុងពីកិច្ចអង្គប្រជុំពេញអង្គនៅព្រឹកថ្ងៃទី២២ តុលា ឆ្នាំ២០២១៕

*ដោយ ម៉ែន ខែមរៈ*

*ប្រភព៖ខេមបូណ្ឌមីសចេញផ្សាយថ្ងៃទី២៤ខែតុលា ឆ្នាំ២០២១។*

## រាជរដ្ឋាភិបាលដាក់ចេញគោលការណ៍គន្លឹះ៥ចំណុចក្នុងការខ្ចី និងគ្រប់គ្រងបំណុល



*ដោយ ខេមបូណូមីស*

នៅក្នុងឆ្នាំ២០២២ខាងមុខនេះ រាជរដ្ឋាភិបាលកម្ពុជាមានផែនការនឹងបង្កើនទំហំនៃការខ្ចីប្រាក់ពីដៃគូអភិវឌ្ឍន៍បន្ថែមទៀត រហូតដល់ ១ ៦០០លាន SDR (ជាតម្លៃរូបិយវត្ថុដែលកំណត់ដោយ IMF) ស្មើនឹងប្រមាណជាង២ ២០០លានដុល្លារអាមេរិក(កើនឡើងពី ១០០លាន SDR ឬស្មើនឹងជាង១៤០លានដុល្លារអាមេរិក) បើធៀបនឹងច្បាប់ថវិកាឆ្នាំ២០២១។

រាជរដ្ឋាភិបាលកម្ពុជាអះអាងថា ស្ថានភាពបំណុលរបស់កម្ពុជា ត្រូវបានវាយតម្លៃថា មានចីរភាព និងហានិភ័យកម្រិតទាបនៅឡើយទេ។

នៅក្នុងការគ្រប់គ្រងបំណុលសាធារណៈ រាជរដ្ឋាភិបាលបានប្រកាន់ខ្ជាប់នូវគោលការណ៍គន្លឹះ៥ចំណុច ៖

១. ខ្ចីឥណទានក្នុងទំហំសមស្របដែលស្ថានភាពថវិកា និងសេដ្ឋកិច្ចអាចទ្រាំទ្របាន

២. ខ្ចីតែឥណទានដែលមានកម្រិតសម្បទាន ឬលក្ខខណ្ឌអនុគ្រោះខ្ពស់

៣. ខ្ចីសម្រាប់តែវិស័យអាទិភាពទ្រទ្រង់ចីរភាព នៃកំណើនសេដ្ឋកិច្ច និងវិស័យបង្កើនផលិតភាពសេដ្ឋកិច្ច ឬផលិតភាពផលិតកម្ម

៤. ប្រើប្រាស់ឥណទានដោយតម្លាភាព គណនេយ្យភាព ប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពខ្ពស់បំផុត

៥. ប្រើប្រាស់ឥណទានសម្រាប់ហិរញ្ញប្បទានគម្រោងវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ដែលត្រូវមានស្តង់ដារ និងគុណភាពខ្ពស់ ស្របតាមគោលការណ៍នៃការគ្រប់គ្រងការវិនិយោគសារធារណៈ ព្រមទាំងឆ្លើយតបទៅនឹងតម្រូវការនៃការអភិវឌ្ឍជាតិ នៅក្នុងដំណាក់កាលថ្មី ពិសេសធានាបាននូវចីរភាពសេដ្ឋកិច្ច សង្គម បរិស្ថាន និងភាពធន់នឹងបម្រែបម្រួលអាកាសធាតុ។

គិតត្រឹមឆមាសទី១ឆ្នាំ២០២១ កម្ពុជាមានសន្និធិបំណុលសាធារណៈសរុបជាង៩ពាន់លានដុល្លារអាមេរិក ដោយក្នុងនោះ ប្រទេសចិនមានដល់ទៅជិត៤៤%នៃបំណុលសាធារណៈសរុប បន្ទាប់មក គឺបំណុលដែលខ្ចីពីពហុភាគីដែលមានជាង ៣០% និងបំណុលជំពាក់ប្រទេសជប៉ុនមានជិត៩%, កូរ៉េខាងត្បូងមានជាង៥% និងបំណុលមរតកដែលកំពុងចរចាមានប្រមាណជាង ៦,៧%។ នេះបើតាមតួលេខពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ *ដោយ ម៉ែន ខេមរៈ*

*ប្រភព៖ខេមបូណូមីសចេញផ្សាយថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២១។*

## រាជរដ្ឋាភិបាលកម្ពុជា គ្រោងធ្វើការបោះផ្សាយលក់នូវមូលបត្ររដ្ឋដែលមានតម្លៃ ៣០០លានដុល្លារនៅ ឆ្នាំក្រោយនេះ




*ប្រភព៖khmertimeskh, 2021*

នៅឆ្នាំ២០២២ខាងមុខនេះ រាជរដ្ឋាភិបាលកម្ពុជាមានគោលដៅក្នុងការបោះផ្សាយលក់មូលបត្ររដ្ឋដែលមានលក្ខណៈអធិបតេយ្យភាពជាលើកដំបូងបង្អស់ក្នុងទំហំទឹកប្រាក់ ៣០០ លានដុល្លារ ដើម្បីប្រមូលមូលនិធិផ្តល់ហិរញ្ញប្បទានដល់គម្រោងវិនិយោគសាធារណៈ ក្នុងគោលបំណងជំរុញកំណើនសេដ្ឋកិច្ច និងផលិតភាពរបស់ប្រទេស។

ការចេញផ្សាយនូវសញ្ញាបណ្ណអធិបតេយ្យភាពគឺជាផ្នែកមួយនៃការកាត់បន្ថយប្រាក់កម្ចីពីបរទេស ដោយរាជរដ្ឋាភិបាលផ្តោតលើការកៀងគរប្រភពហិរញ្ញវត្ថុក្នុងស្រុក។

លើសពីនេះមូលនិធិពីមូលបត្ររដ្ឋនឹងបន្ថែមលើកម្ចីសម្បទានពីដៃគូអភិវឌ្ឍន៍សម្រាប់ឆ្នាំ ២០២២ ដែលមានទំហំ នៃ ១,៦ប៊ីលានSDR សមាមាត្រនឹង ២,២ ប៊ីលានដុល្លារ ក្នុងគោលបំណង ដើម្បីគាំទ្រគម្រោងវិនិយោគសាធារណៈចំនួន៣៥ ដែលទាក់ទងនឹងផ្នែកថាមពល ប្រព័ន្ធធារាសាស្ត្រ ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងវិស័យអាទិភាពផ្សេងទៀត។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានបញ្ជាក់ថា ការចេញបោះផ្សាយលក់មូលបត្ររដ្ឋដែលមានលក្ខណៈអធិបតេយ្យភាព និងកម្ចី មិនបង្កើតបន្ទុកបំណុលដល់កម្ពុជាឡើយ។ បច្ចុប្បន្នស្ថានភាពបំណុលសាធារណៈរបស់កម្ពុជានៅតែមានហានិភ័យទាប ដោយសារសូចនាករបំណុលសំខាន់ៗគឺទាបជាងកម្រិតអនុបាតគោល៕

*ដោយ សេន ចន្ទី*

*ប្រភព៖khmertimeskh. ចេញផ្សាយថ្ងៃទី២៦ខែតុលា ឆ្នាំ២០២១*

## ផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តសៀមរាប នឹងផ្តល់ផ្លែផ្កាអ្វីខ្លះដល់សេដ្ឋកិច្ចកម្ពុជា?



*រូបភាព ខេមបូណ្ឌមីស*

រាជរដ្ឋាភិបាលកម្ពុជា បានប្រកាសដាក់ឱ្យអនុវត្តផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តសៀមរាប២០២១-២០៣៥ ជាផ្លូវការហើយ។ ផែនការមេនេះ គឺជាឯកសារយុទ្ធសាស្ត្រដ៏សំខាន់ ដែលឆ្លុះបញ្ចាំងពីចក្ខុវិស័យវែងឆ្ងាយនៃការអភិវឌ្ឍន៍វិស័យទេសចរណ៍នៅខេត្តសៀមរាប និងតំបន់ជុំវិញខេត្តសៀមរាបទាំងមូល។ ផែនការមេនេះនឹងប្រែក្លាយខេត្តសៀមរាប ជាគោលដៅទេសចរណ៍អន្តរជាតិដ៏ទាក់ទាញ ប្រកបដោយគុណភាព ផ្តល់នូវធនធានទេសចរណ៍សម្បូរបែប មានការទទួលស្គាល់ជាលក្ខណៈសកលលើការអភិរក្ស និងកិច្ចគាំពារសម្បត្តិបេតិកភណ្ឌវប្បធម៌ និងបរិស្ថានធម្មជាតិ។

ផែនការមេបានកំណត់រួមបញ្ចូលទាំងទេសចរណ៍វប្បធម៌ និងទេសចរណ៍ធម្មជាតិ ដែលបច្ចុប្បន្ន ការទស្សនាប្រាសាទអង្គរ គឺជាមូលហេតុចម្បងតែមួយរបស់ភ្ញៀវទេសចរដែលមកកាន់ខេត្តសៀមរាប។ ក្នុងន័យនេះ ផែនការមេខេត្តសៀមរាប នឹងជួយបង្កើនភាពទាក់ទាញខេត្តសៀមរាប និងមានសកម្មភាពកម្សាន្តដ៏សម្បូរបែប ដើម្បីទាញយកនូវតម្លៃបន្ថែមកាន់តែខ្ពស់ពីវិស័យទេសចរណ៍។

ដើម្បីសម្រេចនូវគោលបំណងនូវផែនការខាងលើ ផែនការត្រូវការគោលដៅយុទ្ធសាស្ត្រសំខាន់ៗ ដូចជា ការអភិវឌ្ឍតំបន់ទេសចរណ៍អាទិភាព ការអភិវឌ្ឍផលិតផលទេសចរណ៍ថ្មីៗ ការផ្សព្វផ្សាយ និងទាក់ទាញទេសចរណ៍ ការពង្រឹងគុណភាព និងនិរន្តរភាពនៃការអភិវឌ្ឍទេសចរណ៍ ការគ្រប់គ្រងបរិស្ថាន ការអភិវឌ្ឍហេដ្ឋារចនាសម្ពន្ធ និងពង្រឹងការតភ្ជាប់គាំទ្រវិស័យទេសចរណ៍ និងការពង្រឹងអភិបាលកិច្ចសម្រាប់ទ្រទ្រង់ការអភិវឌ្ឍវិស័យទេសចរណ៍នៅខេត្តសៀមរាប ដោយឈរលើអភិក្រមនៃការចូលរួម។

ប្រធានសមាគមទីភ្នាក់ងារទេសចរណ៍អាស៊ីប៉ាស៊ីហ្វិក និងប្រធានសមាគមសណ្ឋាគារកម្ពុជា បានមើលឃើញថា ផែនការមេអភិវឌ្ឍន៍ខេត្តសៀមរាបនេះ គឺជាឱកាសបន្ថែម ក្នុងការជួយឱ្យវិស័យទេសចរណ៍កម្ពុជាងើបឡើងវិញ។ ប៉ុន្តែក្រោយរាជរដ្ឋាភិបាលប្រកាសជាផ្លូវការភ្លាមៗនូវផែនមេ មិនទាន់អាចឱ្យវិស័យនេះប្រសើរឡើងវិញភ្លាមៗនោះទេ។

រដ្ឋមន្ត្រីក្រសួងទេសចរណ៍ មានក្តីរំពឹងខ្ពស់ថា សេដ្ឋកិច្ចកម្ពុជា នឹងប្រសើរឡើងវិញតាមរយៈផែនការមេនេះ ហើយធ្វើឱ្យប្រទេសកម្ពុជា ពិសេសភ្ញៀវទេសចរកាន់តែច្រើននឹងមកកម្សាន្តនៅកម្ពុជា នៅឆ្នាំបន្តបន្ទាប់។

ប្រមុខរាជរដ្ឋាភិបាលកម្ពុជាក៏បានជំរុញឱ្យក្រសួង-ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរខេត្តពង្រឹងលក្ខណៈសម្បត្តិរបស់ខេត្តសៀមរាប ក្នុងការទាក់ទាញភ្ញៀវទេសចរផ្ទៃក្នុង និងភ្ញៀវទេសចរអន្តរជាតិ និង ជំរុញបញ្ចប់គម្រោងកែលម្អផ្លូវ ៣៨ខ្សែ ក្នុងក្រុងសៀមរាបក៏ដូចជា ពង្រឹងនូវការគ្រប់គ្រងលំហូរភ្ញៀវក្នុងតំបន់អង្គរឱ្យស្របតាមគន្លងប្រក្រតីភាពថ្មីផងដែរ៕

*ដោយ ម៉ែន ខែមរៈ*

*ប្រភព៖ខេមបូណូមីសចេញផ្សាយថ្ងៃទី២២ ខែតុលា ឆ្នាំ២០២១។*

## ការអភិវឌ្ឍខេត្តព្រះសីហនុទៅជាតំបន់សេដ្ឋកិច្ចពិសេសគំរូពហុបំណង



*រូបភាព៖ រដ្ឋបាលខេត្តព្រះសីហនុ*

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងវិទ្យាស្ថាននគរូបនីយកម្ម និងឌីសាញស៊ិនជិន(UPDIS) បានចុះហត្ថលេខាលើកិច្ចសន្យាផ្តល់សេវាកម្មរៀបចំផែនការមេអភិវឌ្ឍន៍ខេត្តព្រះសីហនុឱ្យក្លាយទៅតំបន់សេដ្ឋកិច្ចពិសេសគំរូពហុបំណង។ គោលបំណងនៃការរៀបចំផែនការមេនេះ គឺដើម្បីជំរុញការអភិវឌ្ឍវិស័យឧស្សាហកម្មកម្ពុជាឱ្យមានភាពរីកចម្រើនប្រកបដោយចីរភាព និងបរិយាប័ន្ន។ ការអភិវឌ្ឍនេះ គឺជាផ្នែកមួយក្នុងការរៀបចំយុទ្ធសាស្ត្ររយៈពេលមធ្យម និងវែង ដើម្បីជំរុញការអភិវឌ្ឍប្រកបដោយចីរភាព និងបរិយាប័ន្ន ស្របតាមគោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មកម្ពុជាឆ្នាំ ២០១៥-២០២៥ ដើម្បីសម្រេចបានចក្ខុវិស័យក្នុងការប្រែក្លាយកម្ពុជាឱ្យក្លាយជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងមានចំណូលកម្រិតខ្ពស់នៅឆ្នាំ២០៥០។

ក្នុងចំណោមប៉ូលសេដ្ឋកិច្ចសំខាន់របស់កម្ពុជា ខេត្តព្រះសីហនុជាខេត្តមានសក្តានុពលសម្រាប់ការអភិវឌ្ឍ ត្បិតខេត្តនេះមានទីតាំងភូមិសាស្ត្រល្អ កំពង់ផែ អាកាសយានដ្ឋានអន្តរជាតិ និងតំបន់ឆ្នេរទេសចរណ៍ជាច្រើនទៀត។ នៅពេលអនាគតខាងមុខ ខេត្តព្រះសីហនុនេះ

នឹងក្លាយជាច្រកសេដ្ឋកិច្ចដ៏សំខាន់របស់កម្ពុជា ដើម្បីនាំចេញទំនិញផ្ទាល់ទៅកាន់ទីផ្សារបរទេស លែងពឹងតែលើច្រកប្រទេសវៀតណាម ឬថៃ ទៀត។ រាជរដ្ឋាភិបាលបានដាក់ចេញនូវផែនការចំនួន៤ចំណុច ដើម្បីប្រែក្លាយខេត្តព្រះសីហនុ ទៅជាតំបន់សេដ្ឋកិច្ចពិសេសគំរូពហុបំណង និងជាប៉ូលសេដ្ឋកិច្ចដ៏សំខាន់ក្នុងការទាក់ទាញការវិនិយោគពីបរទេស រួមមាន ការអភិវឌ្ឍខេត្តព្រះសីហនុឱ្យក្លាយជាទីក្រុងដ៏ល្បី និងសំខាន់មួយនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ តំបន់ដែលប្រើប្រាស់បច្ចេកវិទ្យាវ័យឆ្លាត និងបំពាក់ដោយសេវាសាធារណៈ បរិក្ខាសម្រាប់រស់នៅលំដាប់ពិភពលោក, តំបន់ប្រកបដោយបរិស្ថានបៃតង និងតំបន់ឧស្សាហកម្មដែលមានតម្លៃបន្ថែមខ្ពស់ចូលរួមបម្រើខ្សែសង្វាក់ផលិតកម្មក្នុងតំបន់ និងសកលលោក និងជាប៉ូលសេដ្ឋកិច្ចដ៏សំខាន់ក្នុងការផ្តល់ការងារដល់ប្រជាពលរដ្ឋ និងជាប្រភពចំណូលជាតិសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជាទាំងមូល។ រាជរដ្ឋាភិបាលបានត្រៀមជាស្រេចដើម្បីអភិវឌ្ឍខេត្តជាប់មាត់សមុទ្រមួយនេះ ដោយចំណាយទុនរាប់រយលានដុល្លារអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ។

អ្នកជំនាញក្នុងវិស័យអចលនទ្រព្យជឿជាក់ថា ផែនការមេអភិវឌ្ឍនេះនឹងជួយទាក់ទាញវិនិយោគិនបរទេសបោះទុនវិនិយោគកាន់តែច្រើនបន្ថែមទៀត នឹងជួយលើកមុខមាត់ខេត្តព្រះសីហនុឱ្យក្លាយជាបណ្តុំឧស្សាហកម្ម ពាណិជ្ជកម្ម និងទេសចរណ៍ដ៏សម្បូរបែប។ អគ្គនាយកក្រុមហ៊ុនអចលនទ្រព្យ CPL ក៏ចាត់ទុកគម្រោងអភិវឌ្ឍនេះនឹងដើរតួនាទីជាចលករ និងជាមេដែកដ៏សំខាន់មួយក្នុងការស្រូបទាញក្រុមហ៊ុនវិនិយោគបរទេសចូលមកកម្ពុជា។ លើសពីនេះទៀត វានឹងជួយពាំនាំមកជាមួយនូវបច្ចេកវិទ្យា និងនវានុវត្តន៍ថ្មីៗ មកកាន់កម្ពុជាផងដែរ ដែលវានឹងជួយប្រែក្លាយខេត្តព្រះសីហនុឱ្យក្លាយជាបណ្តុំឧស្សាហកម្ម ពាណិជ្ជកម្ម និងទេសចរណ៍ដ៏ស៊ីវីល័យដូចទីក្រុងធំៗនៅមួយចំនួននៅក្នុងតំបន់ និងលើពិភពលោក៕ *ដោយ ម៉ែន ខែមរៈ*
*ប្រភព៖ខេមបូណូមីសចេញផ្សាយថ្ងៃទី២០ខែតុលា ឆ្នាំ២០២១។*

## កសិករដាំស្វាយមួយចំនួន បេះក្តឹបស្វាយផ្គត់ផ្គង់ទីផ្សារម្ហូបក្នុងស្រុក បន្ថយការនាំចូលពីក្រៅប្រទេស



*ប្រភព ៖ freshnews*

សហគមន៍កសិកម្មស្វាយកែវរមៀត គិរីរម្យ(កំពង់ស្ពឺ) បានងាកមកបេះក្តឹបស្វាយលក់ក្នុងស្រុកវិញ កាត់បន្ថយការនាំចូលក្តឹបស្វាយពីក្រៅប្រទេស។ នាយកប្រតិបត្តិសហគមន៍ បានជំរុញសមាជិករបស់សមាគមបេះក្តឹបស្វាយ មួយផ្នែកចេញមកលក់ ដោយរក្សាទុកតែបរិមាណតិចតួចក្នុងមួយទងសំរាប់ខ្ចប់ ដើម្បីឲ្យស្វាយមានផ្លែធំល្អនិងមានគុណភាពលក់បានតម្លៃថ្លៃ។ តាមការស្រាវជ្រាវរបស់សហគមន៍កសិកម្មស្វាយកែវរមៀតគិរីរម្យ បានឱ្យដឹងថា ក្នុងមួយថ្ងៃកម្ពុជាមានតម្រូវការក្តឹបស្វាយប្រមាណ១០តោនក្នុងមួយថ្ងៃ ហើយក្តឹបស្វាយដែលដាក់លក់តាមហាងម្ហូបនានា គឺនាំចូលពីថៃប្រមាណ៩០% ក្នុងតម្លៃចន្លោះពី២ពាន់រៀល ទៅ៥ពាន់រៀល ក្នុងមួយគីឡូក្រាម។ បច្ចុប្បន្នកំពុងសហការ

ជាមួយនិស្សិតនៃសាកលវិទ្យាល័យគ្រប់គ្រងបាត់ដំបង ដើម្បីស្រាវជ្រាវកែច្នៃធ្វើជ្រក់ក្ដឹបស្វាយ ដែលអាចរក្សាទុកបានមួយឆ្នាំ។

នាយកប្រតិបត្តិសហគមន៍ពើងថា នៅរដូវប្រមូលផលស្វាយ (រដូវជន់ស្វាយ) ក្នុងខែក្នុងកុម្ភៈ ដល់ខែមេសា នឹងមិនមានស្វាយទុំជ្រុះចោលនៅក្រោមដើមទៀតទេ ព្រោះកសិករចេះប្រលេះក្ដឹបស្វាយខ្លះយកមកលក់ និងទុកផ្លែខ្លះសម្រាប់ខ្ចប់ឱ្យមានផ្លែធំល្អ ដើម្បីនាំចេញទៅក្រៅប្រទេស៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព ៖ freshnews ចេញផ្សាយថ្ងៃទី ២០ ខែតុលា ឆ្នាំ២០២១។*

## ក្រុមអ្នកវិនិយោគចិន កំពុងសិក្សាឱកាសវិនិយោគលើការកែច្នៃត្រី ក្នុងខេត្តកំពង់ឆ្នាំង




*ប្រភព ៖ freshnews*

អ្នកវិនិយោគចិន ចាប់អារម្មណ៍ទៅលើវិស័យចិញ្ចឹមត្រី និងបង្កើតរោងចក្រកែច្នៃត្រី នៅខេត្តកំពង់ឆ្នាំង សម្រាប់បំពេញតម្រូវការក្នុងស្រុក និងនាំចេញផងដែរ។ ការសិក្សាបង្កើតរោងចក្រកែច្នៃត្រី ដោយសារខេត្តនេះសម្បូរត្រី និងជាខេត្តជាប់ទន្លេសាប ងាយស្រួលការចិញ្ចឹមត្រី។ គម្រោងនេះក៏ភ្ជាប់ជាមួយកសិករចិញ្ចឹមត្រីនៅក្នុងតំបន់។ វិនិយោគិនចិន ក៏មានរោងចក្រផលិតចំណីត្រី ចំណីសត្វនៅតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ ដែរ និងមានបំណងវិនិយោគបន្ថែមទៅលើការកែច្នៃត្រី។

អភិបាលខេត្ត និងប្រធានក្រុមប្រឹក្សាខេត្ត សង្ឃឹមថា វត្តមានរោងចក្រកែច្នៃត្រីនៅខេត្តកំពង់ឆ្នាំងនេះ នឹងជួយដល់វិស័យចិញ្ចឹមត្រីនៅកម្ពុជា ជាពិសេសជួយទីផ្សារ តម្លៃត្រីរបស់កសិករ និងបញ្ហាត្រី។

ក្រុមអ្នកវិនិយោគ បានទស្សនកិច្ចទីតាំងគម្រោងចញ្ចឹមគោមួយកន្លែង ដែលស្ថិតក្នុងស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង លើផ្ទៃដីប្រមាណ២០០ហិកតា ដែលជំហ៊ានដំបូងវិនិយោគជិតប្រាក់១លានដុល្លារ ដើម្បីចិញ្ចឹមគោយកសាច់៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព ៖ freshnews ចេញផ្សាយថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២១។*

## ការនាំចេញរ៉ែមាសកម្ពុជាផ្ដល់ចំណូលចូលរដ្ឋជាង៦៦ម៉ឺនដុល្លារ ក្រោយដំណើរការបាន៤ខែ



*រូបភាព៖ ក្រសួងរ៉ែ និងថាមពល*

ក្រោយបានដំណើរការបាន៤ខែ ក្រុមហ៊ុនរបស់អូស្ត្រាលី រ៉ឺនេសង់ មីនើរ៉ល (ខេមបូឌា) លីមីតធីត ចម្រាញ់រ៉ែមាសពីតំបន់អូខ្វាវ ស្រុកកែវសីមា ខេត្តមណ្ឌលគិរី បានជាង ៧៤៧ គីឡូក្រាម និងបាននាំចេញចំនួន ៥៥៥ គីឡូក្រាមហើយ។ ក្រុមហ៊ុនបានបង់ចំណូលចូលរដ្ឋប្រមាណ ៦៦ម៉ឺនដុល្លារ និងនាំចេញដុំមាសបានចំនួន ១២ដើង ដើម្បីយកទៅបន្សុទ្ធជាមាសទឹក៩៩,៩៩%

នៅប្រទេសអូស្ត្រាលី។ សម្រាប់ការនាំចេញទាំង១២ជើងនេះ សម្រេចបាន៤៨ដុំមាស និងមានទម្ងន់ប្រមាណ៥៥៥គីឡូក្រាម។ តាមផែនការដែលបានគ្រោងទុក ក្រុមហ៊ុនត្រូវចម្រាញ់រ៉ែមាស ប្រមាណ៣ពាន់គីឡូក្រាម ឬស្មើនឹង៣តោនក្នុងឆ្នាំដំបូង ខណៈត្រឹមរយៈពេល៤ខែនេះ អាចចម្រាញ់រ៉ែមាសជាង ៧រយគីឡូក្រាម។

រយៈពេល៤ខែកន្លងមកនេះ រោងចក្រចម្រាញ់រ៉ែមាសមានដំណើរការដោយរលូន គ្រាន់តែអំឡុងវិបត្តិកូវីដ-១៩ អាជីវកម្មនេះ បានជួបបញ្ហាខ្វះកម្លាំងពលកម្មជំនាញ មួយចំនួន តែមិនបានបង្កជាបញ្ហារាំងស្ទះអ្វីឡើយ ក្នុងដំណើរការក្នុងឧស្សាហកម្មនេះ៕

*ដោយ ម៉ែន ខេមរៈ*

*ប្រភព៖ខេមបូណូមីសចេញផ្សាយថ្ងៃទី២២ ខែតុលា ឆ្នាំ២០២១។*

## អ្នករកស៊ីតាមអនឡាញ នៅតែមិនទាន់មកស្នើសុំអាជ្ញាបណ្ណ ខណៈការផាកពិន័យកាន់តែខិតជិតមកដល់



*ដោយ ខេមបូណូមីស*

មន្ត្រីជាន់ខ្ពស់ក្រសួងពាណិជ្ជកម្មបានអះអាងថា មកទល់ពេលនេះមិនទាន់មានក្រុមហ៊ុន សហគ្រាស ឬ នីតិបុគ្គលដែលប្រកបអាជីវកម្មតាមប្រព័ន្ធអេឡិចត្រូនិក ណាមួយមកស្នើសុំលិខិត ឬអាជ្ញាបណ្ណអាជីវកម្មអេឡិចត្រូនិកនៅក្រសួងនៅឡើយទេ ទោះបីក្រសួងបានជូនដំណឹង និងក្រើនរំលឹកជាច្រើនលើកក្តី។ អ្នកប្រកបអាជីវកម្មតាមប្រព័ន្ធអេឡិចត្រូនិក នឹងប្រឈមការផាកពិន័យជាប្រាក់ ឬបញ្ឈប់អាជីវកម្ម បើបន្តធ្វើដោយគ្មានលិខិត ឬអាជ្ញាបណ្ណអនុញ្ញាតចាប់ពីថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០២១ ខាងមុខ។ បើតាមច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ក្រុមហ៊ុន សហគ្រាស និងបុគ្គល ដែលប្រកបអាជីវកម្មតាមអនឡាញគ្មានលិខិត ឬអាជ្ញាបណ្ណអនុញ្ញាតអាចរកការពិន័យជាប្រាក់១០លានរៀល ផ្អាក ឬបិទអាជីវកម្ម។

ក្រសួងពាណិជ្ជកម្ម បានឃើញមានក្រុមហ៊ុនសហគ្រាស និងអ្នកប្រកបអាជីវកម្មតាមប្រព័ន្ធអេឡិចត្រូនិកជាច្រើនបានមកសួរនាំព័ត៌មាន និងនីតិវិធីក្នុងការស្នើសុំលិខិត ឬអាជ្ញាបណ្ណអាជីវកម្មតាមប្រព័ន្ធអេឡិកនៅក្រសួង ក្រោយក្រសួងដាក់ឱសានវាទអនុវត្តវិធានការផាកពិន័យ។ មកទល់ពេលនេះមិនទាន់ឃើញមកស្នើសុំលិខិត ឬអាជ្ញាបណ្ណអនុញ្ញាតនៅឡើយទេ។ ប៉ុន្តែនឹងមានមួយចំនួនមកចុះបញ្ជីក្នុងពេលឆាប់ៗខាងមុខនេះ បន្ទាប់ពីពួកគេមួយចំនួនបានមកសួរនាំព័ត៌មាន និងពិគ្រោះយោបល់ជាមួយអ្នកជំនាញ។ ការស្នើសុំលិខិតអនុញ្ញាតលក្ខណៈបុគ្គលមានតម្លៃ២០ម៉ឺនរៀល, លក្ខណៈសហគ្រាសឯកបុគ្គលតម្លៃ៤០ម៉ឺនរៀល និងសម្រាប់ក្រុមហ៊ុនតម្លៃ១លានរៀល៕

*ដោយ ម៉ែន ខេមរៈ*

*ប្រភព៖ខេមបូណូមីសចេញផ្សាយថ្ងៃទី២០ខែតុលា ឆ្នាំ២០២១។*

## តារាងប្រចាំសប្តាហ៍

### រូបភាពទី១៖ កំណើនថយចុះ នៃស្ថានវិនិយោគក្រៅតំបន់សេដ្ឋកិច្ចពិសេស

យោងតាមព្រឹត្តិបត្រស្ថិតសេដ្ឋកិច្ច និងហិរញ្ញវត្ថុប្រចាំត្រីមាសទី២ ឆ្នាំ២០២១ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គម្រោងវិនិយោគក្រៅតំបន់សេដ្ឋកិច្ចពិសេស និងទុនវិនិយោគមានការធ្លាក់ចុះ ក្នុងត្រីមាសទី២ ឆ្នាំ២០២១។ គម្រោងវិនិយោគក្រៅតំបន់សេដ្ឋកិច្ចពិសេសសរុបមានចំនួន ២៥ គម្រោង បានធ្លាក់ចុះ ៣០ គម្រោង ឬធ្លាក់ចុះ ៥៥%។ ទន្ទឹមនេះ ទុនវិនិយោគមានចំនួនប្រហែល ២៦២ លានដុល្លារ បានធ្លាក់ចុះ ៧៩% បើធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០២០។ ការធ្លាក់ចុះនេះ គឺដោយសារការធ្លាក់ចុះខ្លាំងលើការ វិនិយោគផ្នែកកាត់ដេរសម្លៀកបំពាក់ ស្បែកជើង ថាមពល សណ្ឋាគារ និងកសិឧស្សាហកម្ម៕ *ដោយ ឈន ហាំ*

**ស្ថានភាពវិនិយោគក្រៅតំបន់សេដ្ឋកិច្ចពិសេស**




ប្រភព៖ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា(CDC)

*ប្រភព៖ ព្រឹត្តិបត្រស្ថិតសេដ្ឋកិច្ច និងហិរញ្ញវត្ថុប្រចាំត្រីមាសទី២ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២១*

### រូបភាពទី២៖ កំណើនថយចុះ នូវចំណូលពន្ធអាករគយ ក្នុងត្រីមាសទី៣ ឆ្នាំ២០២១

យោងតាមទិន្នន័យរបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា(អគរ) បានបង្ហាញថា ការអនុវត្តលើការប្រមូលចំណូល បានថយចុះប្រហែល ៧% ក្នុងរយៈពេល ៩ខែ នៃឆ្នាំ២០២១ បើធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០២០។

គិតត្រឹមក្នុងត្រីមាសទី៣ ឆ្នាំ២០២១នេះ អគរ ប្រមូលចំណូលបានចំនួន ៦ ៨៨១ ប៊ីលានរៀល ស្មើនឹង ១ ៦៩៩ លានដុល្លារ។ ក្នុងនោះដែរ បើគិតតាមប្រភេទពន្ធ និងអាករមួយចំនួន នៃចំណូលសរុបខាងលើនេះ អាករលើតម្លៃបន្ថែមមានប្រមាណ ៣៨,០%, អាករពិសេស ៣៧,៤%, ពន្ធនាំចូល ១៨,១%, អាករបន្ថែមលើផលិតផលប្រេង ៤,៥% និងអាករនាំចេញនិងកម្រៃផ្សេងៗ ២% ។

ដោយឡែក បើគិតតាមក្រុមទំនិញវិញចំណូលសរុបខាងលើ ចំណូលពីយានយន្ត និងគ្រឿងចក្រមានប្រមាណ ៤១,៩% ទំនិញចម្រុះ២៨,៣% ផលិតផលសេលសិលា២៣,៥% និងសម្ភារសំណង់និងកម្រៃផ្សេងៗ ៦,៣% ។

ជាលទ្ធផលការប្រមូលចំណូលក្នុងត្រីមាសទី៣នេះ គឺសម្រេចបាន ៧២% នៃផែនការ ដែលកំណត់ដោយច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២១៕

*ដោយ ឈន ហាំ*

**ចំណូលពន្ធអាករគយប្រចាំ ៩ខែ ឆ្នាំ២០២០ និងឆ្នាំ២០២១**




*ប្រភព៖ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា(អគរ)*

*ប្រភព៖ [របាយការណ៍បូកសរុបលទ្ធផលប្រចាំត្រីមាសទី៣ របស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ចុះថ្ងៃទី២១ ខែតុលា ២០២១]*

## ព័ត៌មាន និងទិន្នន័យរបស់បណ្តាប្រទេសនៅក្នុងអាស៊ាន និងដៃគូពាណិជ្ជកម្មដទៃទៀត

### ពាណិជ្ជកម្មទ្វេភាគីរវាងប្រទេសកម្ពុជា និងប្រទេស ជប៉ុនបានកើនឡើងដល់១,៥ប៊ីលានដុល្លារអាមេរិក គិតត្រឹមរយៈពេល៨ខែដំបូងនៃឆ្នាំ២០២១



*ប្រភព៖phnompenhpost, 2021 រូបភាព៖ ម៉ៃ គុណមករា*

យោងតាមទិន្នន័យរបស់អង្គការពាណិជ្ជកម្មក្រៅប្រទេសជប៉ុន(Jetro)បានបង្ហាញថា៖ពាណិជ្ជកម្មទ្វេភាគីរវាងកម្ពុជា និងជប៉ុនឈានដល់ ១,៥ ប៊ីលានដុល្លារក្នុងរយៈពេល ៨ ខែដំបូងនៃឆ្នាំ ២០២១ កើនឡើង ១១,៨% ធៀបនឹងរយៈពេលដូចគ្នានៃឆ្នាំ២០២០ដែលមានតម្លៃ ១,៣៥ប៊ីលានដុល្លារ ។

សម្រាប់ការនាំចេញរបស់ប្រទេសកម្ពុជាទៅកាន់ប្រទេសជប៉ុនមានចំនួន ១,១២ប៊ីលានដុល្លារ កើនឡើងជាង៧% ធៀបនឹងរយៈពេលដូចគ្នានៃឆ្នាំមុនដែលមានទំហំ ១,០៤ ប៊ីលានដុល្លារ ហើយការនាំចូលមានតម្លៃ ៣៨៥,១៤ លានដុល្លារ កើនឡើង ២៨%ធៀបនឹងឆ្នាំ២០២០ ដែលមានតម្លៃ ៣០០,៩ លានដុល្លារ។

តាមរយៈស្ថិតិទាំងនេះបញ្ជាក់ថាអតិរេកពាណិជ្ជកម្មបានធ្លាក់ចុះ១,២% សមាមាត្រ ៧៣៩,១ លានដុល្លារ គិតពីខែមករាដល់ខែសីហាពីទំហំ៧៤៨ លានដុល្លារក្នុងរយៈពេលដូចគ្នានៃ២០២០ ។ Jetro បានចុះបញ្ជីផលិតផល សម្លៀកបំពាក់ និងគ្រឿងបន្លាស់អគ្គិសនី និងអេឡិចត្រូនិច ជាការនាំចេញដ៏សំខាន់របស់កម្ពុជាទៅកាន់ប្រទេសជប៉ុន និងគ្រឿងម៉ាស៊ីន គ្រឿងអេឡិចត្រូនិច និងផលិតផលបច្ចេកវិទ្យាខ្ពស់ ដែលជាការនាំចូលសំខាន់។

ទន្ទឹមនឹងនេះ អនុប្រធានសភាពាណិជ្ជកម្មកម្ពុជា បានកត់សម្គាល់ថា ទោះបីជាវិបត្តិកូវីដ-១៩ ពិភពលោកកាន់តែតានតឹងក៏ដោយ ការនាំចូល និងការនាំចេញរវាងប្រទេសទាំងពីរ បានចាប់ផ្តើមកើនឡើងជាលំដាប់បន្ទាប់ពីមានការធ្លាក់ចុះ។ តួលេខនាំចូល និងនាំចេញដែលបានកត់ត្រាតាំងពីដើមឆ្នាំ២០២១ ជាសញ្ញាសន្យាសម្រាប់ស្ថានភាពទូទៅនៃទំនាក់ទំនងពាណិជ្ជកម្មកម្ពុជា-ជប៉ុន ដែលនឹងទទួលបានសន្ទុះកើនឡើង នៅពេលដែលការហោះហើរត្រង់រវាងប្រទេសទាំងពីរចាប់ផ្តើមឡើងវិញ។

បន្ទាប់ពីបង្កើតកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី (FTA) ជាមួយចិន និងកូរ៉េខាងត្បូង ប្រទេសកម្ពុជាក៏នឹងអាច

ឈានដល់កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីជាមួយជប៉ុន ផងដែរ ។ នៅពេលកិច្ចព្រមព្រៀងនេះចូលជាធរមាន ការនាំចេញ និងការនាំចូលរវាងប្រទេសទាំងពីរប្រាកដជានឹងកើនឡើងកាន់តែលឿនជាងពេលបច្ចុប្បន្ន។

ការនាំចូលទាំងនេះភាគច្រើនជាគ្រឿងម៉ាស៊ីន និងឧបករណ៍អេឡិចត្រូនិក ដែលជាចំណែកដ៏ច្រើនសន្ធឹកសន្ធាប់ដែលប្រើប្រាស់នៅក្នុងសង្វាក់ផលិតកម្ម ដែលនាំចេញទំនិញដែលកំណត់សម្រាប់ទីផ្សារក្រៅប្រទេស។

ទិន្នន័យរបស់ Jetro បង្ហាញថា ពាណិជ្ជកម្មទ្វេភាគីរវាងកម្ពុជា និងជប៉ុនបានកើនឡើងដល់ ២,១ប៊ីលានដុល្លារ កាលពីឆ្នាំមុន ធ្លាក់ចុះ ៨,៣៥%ធៀបនឹងឆ្នាំ ២០១៩។ ការនាំចេញរបស់កម្ពុជាមាន ១,៦ ប៊ីលានដុល្លារក្នុងឆ្នាំ ២០២០ ធ្លាក់ចុះ ៦,៦% ហើយការនាំចូលមានចំនួន ៤៨៤,៧ លានដុល្លារ ធ្លាក់ចុះ ១៣,៨% ធៀបនឹងឆ្នាំ ២០១៩។ អតិរេកពាណិជ្ជកម្មរបស់ប្រទេសកម្ពុជាជាមួយប្រទេសជប៉ុនមានចំនួន ១,១៣ប៊ីលានដុល្លារ៕ *ដោយ សេន ចន្នី*

*ប្រភព៖phnompenhpost.ចេញផ្សាយថ្ងៃទី២៥ខែតុលាឆ្នាំ២០២១*

## អតិរេកពាណិជ្ជកម្មរបស់ឥណ្ឌូនេស៊ី សម្រាប់ខែកញ្ញា ឆ្នាំ ២០២១ (គិតជាពាន់លានដុល្លារ)

ការនាំចេញទំនិញសរុបរបស់ប្រទេសឥណ្ឌូនេស៊ីមានចំនួន ២០,៦០ ពាន់លានដុល្លារ នៅក្នុងខែកញ្ញា ឆ្នាំ ២០២១ ធៀបទៅនឹងខែរយៈពេលដូចគ្នាកាលពីឆ្នាំមុន បានកើនឡើង៤៧,៦៤%។ ការនាំចេញ ដែលមានទំហំធំបំផុត គឺផលិតផលមិនមែនប្រេង និងឧស្ម័ន ដែលបានរួមចំណែក ១៩,៦៧ ពាន់លានដុល្លារ ក្នុងនោះនាំចេញទៅចិន (៤,៥៤ ពាន់លានដុល្លារ) សហរដ្ឋអាមេរិក (២,៣៤ ពាន់លានដុល្លារ) និងជប៉ុន (១,៥៤ ពាន់លានដុល្លារ) ស្មើនឹង ៤២,៨៣%។ រីឯ ការនាំចូលសរុបមានទំហំ ១៦,២៣ ពាន់លានដុល្លារ នៅក្នុងខែកញ្ញា ឆ្នាំ២០២១ បើធៀបទៅនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន បានកើនឡើង ៤០,៣១%។ ការនាំចូលភាគច្រើន គឺផលិតផលមិនមែនប្រេង និងឧស្ម័ន ដែលមាន ១៤,៣៧ ពាន់លានដុល្លារ បើធៀបទៅនឹងខែដូចគ្នាកាលពីឆ្នាំ២០២០ បានកើនឡើង ៣៨,១៨%។ ជារួម ប្រទេសឥណ្ឌូនេស៊ីនៅតែមានអតិរេកពាណិជ្ជកម្ម ៤,៣៧ ពាន់លានដុល្លារអាមេរិក នៅក្នុងខែកញ្ញា ឆ្នាំ ២០២១ ថ្វីបើការនាំចេញ និងការនាំចូលបានធ្លាក់ចុះ ៣,៨៤% និង២,៦៧% រៀងគ្នា ធៀបទៅនឹងខែសីហា ឆ្នាំ២០២១៕ *ដោយ ជីម ប៊ុនធឿន*

| | ទំហំជួញដូរ |
|---|---|
| ការនាំចូល | ២០,៦០ |
| ការនាំចេញ | ១៦,២៣ |
| តុល្យភាពពាណិជ្ជកម្ម | ៤,៣៧ |

*ប្រភព៖ bps*

## ពាណិជ្ជកម្មអន្តរជាតិវៀតណាម សម្រាប់រយៈពេល ០៨ ខែដំបូង នៃឆ្នាំ២០២១ (គិតជាពាន់លានដុល្លារ)

យោងតាមស្ថិតិគយប្រទេសវៀតណាមបានបង្ហាញថា ពាណិជ្ជកម្មសរុបរបស់ប្រទេសវៀតណាម មានចំនួន ៤២៩,៦៨ ពាន់លានដុល្លារ សម្រាប់រយៈពេល០៨ខែ ដំបូងនៃឆ្នាំ២០២១ ពោលគឺ កើនឡើង២៧,៥% ធៀបទៅនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន។

ការនាំចេញទំនិញសរុបមានចំនួន ២១៣,៥២ ពាន់លានដុល្លារ សម្រាប់រយៈពេល ០៨ ខែដំបូង នៃឆ្នាំ២០២១ ពោលគឺ កើនឡើង ២១,៨% បើធៀបទៅនឹងរយៈពេលដូចគ្នាកាលពីឆ្នាំ២០២០។ ការកើនឡើងនេះ រួមចំណែកដោយ ម៉ាស៊ីន គ្រឿងបរិក្ខា និងឧបករណ៍ (tools and instruments) កើនឡើង ៧,៧៨ ពាន់លានដុល្លារ កុំ

ព្យូទ័រ ផលិតផលអគ្គិសនី គ្រឿងបន្លាស់ និងគ្រឿងបង្គុំកើន ឡើង៤,០៩ ពាន់លានដុល្លារ ដែកនិងដែកថែបកើនឡើង ៣,៩៥ ពាន់លានដុល្លារ ទូរស័ព្ទ និងគ្រឿងបន្លាស់កើនឡើង ៣,៧៥ ពាន់លានដុល្លារ។

ខណៈការនាំចូលទំនិញសរុបមានចំនួន ២១៦,១៥ ពាន់លានដុល្លារ សម្រាប់រយៈពេល ០៨ខែដំបូង នៃឆ្នាំ២០២១ ពោលគឺ កើនឡើង ៣៣,៧% ធៀបទៅនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន។ កំណើន នៃការនាំចូលរួមចំណែកជាចម្បងដោយ គ្រឿងបរិក្ខា និងឧបករណ៍ (tools and instruments) កើនឡើង ៨,១៦ ពាន់លានដុល្លារ កុំព្យូទ័រ ផលិតផលអគ្គិសនី គ្រឿងបន្លាស់ និងគ្រឿងបង្គុំកើនឡើង ៨,០៨ ពាន់លានដុល្លារ ទូរស័ព្ទ និងគ្រឿងបន្លាស់កើនឡើង ៣,៨២ ពាន់លានដុល្លារ។

ជារួម តុល្យភាពពាណិជ្ជកម្មវៀតណាមមានឱនភាពចំនួន ២,៦៣ ពាន់លានដុល្លារ សម្រាប់ខែមករា ដល់ ខែសីហា ឆ្នាំ២០២១ ៕ *ដោយ ធីម ប៊ុនធឿន*

| | ទំហំជួញដូរ |
|---|---|
| ការនាំចេញ | ២១៣,៥២ |
| ការនាំចូល | ២១៦,១៥ |
| តុល្យភាពពាណិជ្ជកម្ម | - ២,៦៣ |

*ប្រភព៖ Vietnam Customs*

## សេដ្ឋកិច្ចកូរ៉េខាងត្បូង មានកំណើនយឺតជាងការរំពឹងទុកនៅក្នុងត្រីមាសទី៣ ឆ្នាំ២០២១



*ប្រភព៖ Reuters ២០២១, រូបភាព៖ Kim Hong-Ji*

យោងតាមទិន្នន័យចេញផ្សាយរបស់ធនាគារជាតិកូរ៉េខាងត្បូង (BOK) បានបង្ហាញថាកំណើនផ.ស.ស. របស់កូរ៉េខាងត្បូងដែលត្រូវបានកែសម្រួលតាមរដូវកាលមានចំនួន ០,៣% នៅក្នុងត្រីមាសទី៣ ឆ្នាំ២០២១។ កំណើននេះ គឺយឺតជាងការរំពឹងទុក និងជាកំណើនយឺតបំផុតក្នុងរយៈពេល ៥ត្រីមាស បន្ទាប់ពីកើនឡើងក្នុងអត្រា ០,៨% នៅក្នុងត្រីមាសទី២ ឆ្នាំ២០២១ ខណៈអត្រានេះក៏ទាបជាងការស្ទង់មតិរបស់ Reuters ដែលមានចំនួន ០,៦% ផងដែរ។

ការថមថយនៃកំណើននេះ គឺដោយសារការធ្លាក់ចុះនៃចំណាយឯកជន ដែលរួមចំណែកជិតពាក់កណ្ដាលនៃផ.ស.ស. របស់កូរ៉េខាងត្បូងដល់-០,៣% នៅក្នុងត្រីមាសទី៣ ដែលធ្លាក់ចុះពី ៣,៦% នៅក្នុងត្រីមាសទី២ ឆ្នាំ២០២១ ក៏ដូចជាការធ្លាក់ចុះការវិនិយោគលើវិស័យសំណង់ និងគ្រឿងបរិក្ខាសំណង់ចំនួន-៣,០% និង-២,៣% រៀងគ្នា។ ទោះយ៉ាងនេះក្តី ការថមថយបានប៉ះប៉ូវមកវិញជាមួយនឹងកំណើននៃការនាំចេញក្នុងអត្រា ១,៥% កើនឡើងវិញពីការធ្លាក់ចុះ -២,០% នៅក្នុងត្រីមាសទី២ ឆ្នាំ២០២១ ដោយសារការនាំចេញដ៏រឹងមាំនៃ

វត្ថុធាតុឧបករណ៍អគ្គិសនីពាក់កណ្ដាល (semiconductors) និងអនុផលពីប្រេង។ ជាមួយគ្នានេះ BOK រំពឹងថាកំណើនផ.ស.ស. ប្រចាំឆ្នាំ ២០២១ អាចនឹងមានកំណើន ៤% ប្រសិនបើសេដ្ឋកិច្ចកូរ៉េខាងត្បូងកើនឡើងក្នុងអត្រា ១,០៤% ផ្អែកតាមមូលដ្ឋានធៀបប្រចាំត្រីមាស ក្នុងត្រីមាសទី៤ ឆ្នាំ២០២១។ ទោះជាយ៉ាងណា ក្រុមអ្នកសេដ្ឋកិច្ចមានការព្រួយបារម្ភពីការរំខាននៃខ្សែសង្វាក់ផ្គត់ផ្គង់សកល និងសម្ពាធអតិផរណា ដែលអាចបង្កហានិភ័យដល់ទស្សនវិស័យនៅក្នុងត្រីមាសទី៤ ឆ្នាំនេះ។ យោងតាមលោក Oh Suk-tae សេដ្ឋវិទូនៃក្រុមហ៊ុន Societe Generale បានឱ្យដឹងថា «ទស្សនវិស័យរយៈពេលខ្លីសម្រាប់ការនាំចេញ និងវិស័យផលិតកម្មទំនងជានឹងរងប៉ះពាល់ដោយសារការបន្តការព្រួយបារម្ភអំពីបញ្ហាការផ្គត់ផ្គង់សកល»។ ជាដំណោះស្រាយ រដ្ឋាភិបាលកូរ៉េខាងត្បូងបានដាក់ចេញនូវផែនការលុបចោលវិធានការទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ ឱ្យបានត្រឹមដើមឆ្នាំ២០២២ ដែលមាន ៣ដំណាក់កាល និងចាប់ផ្ដើមអនុវត្តន៍នៅថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០២១ ខាងមុខនេះ ដើម្បីជំរុញដល់ការចំណាយឯកជនក្នុងការរួមចំណែកដល់ការស្តារឡើងវិញនៃសេដ្ឋកិច្ច។ បន្ថែមពីនេះ រដ្ឋាភិបាលក៏បានដាក់ចេញនូវគោលនយោបាយកាត់ពន្ធប្រេងជាបណ្ដោះអាសន្នលើផលិតផលប្រេងសំខាន់ៗចំនួន ២០% ដើម្បីកាត់បន្ថយសម្ពាធពីការកើនឡើងនៃតម្លៃប្រេង៕

*ដោយ ស៊ិន សុភារ៉ា*

*ប្រភព៖ គេហទំព័រសារព័ត៌មានReuters ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២១*

## ប្រទេសឥណ្ឌូនេស៊ី មើលឃើញកំណើនផ.ស.ស. របស់ខ្លួនក្នុងអត្រា ៤,៥% នៅក្នុងត្រីមាសទី៣ ឆ្នាំ២០២១



*ប្រភព៖ CNA ២០២១, រូបភាព៖ AP/Achmad Ibrahim*

សេដ្ឋកិច្ចប្រទេសឥណ្ឌូនេស៊ី ត្រូវបានរំពឹងថានឹងមានកំណើន ៤,៥% នៅក្នុងត្រីមាសទី៣ ឆ្នាំ២០២១ ពេលគឺល្អប្រសើរជាងការព្យាករណ៍ពីមុនជាមួយនឹងកំណើនក្នុងរង្វង់ពី ៤%-៥% ដោយសារកំណើននៃការនាំចេញ និងការងើបឡើងវិញនៃការចំណាយគ្រួសារ ខណៈវិធានការទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ បានចាប់ផ្ដើមបន្ធូរបន្ថយ នេះបើយោងតាមប្រសាសន៍របស់លោកស្រី Sri Mulyani Indrawati រដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុឥណ្ឌូនេស៊ី នៅក្នុងសន្និសីទសារព័ត៌មានតាមអ៊ីនធឺណេតកាលពីពេលថ្មីៗនេះ។

លោកស្រី បញ្ជាក់ថាការនាំចេញរបស់ប្រទេសឥណ្ឌូនេស៊ី ដែលជាប្រទេសនាំចេញធ្យូងថ្មកម្ដៅ និងប្រេងដូងធំជាងគេនៅលើសកលលោកបានកើនឡើងចំពេលតម្លៃកំពុងឡើងខ្ពស់បំផុត ដែលនេះបង្ហាញថាសេដ្ឋកិច្ចរបស់ប្រទេសឥណ្ឌូនេស៊ីកំពុងកើនឡើង និងបានបន្ថែមថាផលប៉ះពាល់សេដ្ឋកិច្ចដោយសារការឆ្លងជាថ្មីនៃជំងឺកូវីដ-១៩ ត្រូវបានគេមើលឃើញថា «មិនជ្រៅពេកទេ»។ ទន្ទឹមនឹងនេះ លោកស្រីក៏បានផ្ដល់ការព្យាករណ៍ផ្លូវការថ្មីមួយសម្រាប់កំណើនសេដ្ឋកិច្ចប្រចាំឆ្នាំ២០២១ ថានឹងមានកំណើន ៤,០% ធៀបនឹងការព្យាករណ៍ពីមុន

ដែលមានក្នុងរង្វង់៣,៧% ទៅ ៤,៥%។ សម្រាប់កំណើនផ.ស.ស. នៅក្នុងត្រីមាសទី៤ ឆ្នាំ២០២១ នៅតែមានសក្តានុពលនៃកើនឡើង បើទោះបីជាកើនជាងអត្រាធម្មតាបន្តិចក៏ដោយ។

ដោយឡែក ក្រុមអ្នកវិភាគបានព្យាករណ៍ថាសេដ្ឋកិច្ចរបស់ប្រទេសឥណ្ឌូនេស៊ីនឹងកើនឡើងក្នុងអត្រា ៣,២% នៅក្នុងត្រីមាសទី៣ ឆ្នាំ២០២១ និង ៤,៦% នៅក្នុងត្រីមាសបច្ចុប្បន្ន ខណៈ កំណើនប្រចាំឆ្នាំ២០២១ ត្រូវបានព្យាករណ៍ថានឹងមានកំណើន ៣,៤% នេះបើយោងតាមការស្ទង់មតិរបស់ Reuters នៅខែតុលា ឆ្នាំ ២០២១ នេះ។

ទោះយ៉ាងណា លទ្ធភាពនៃការធ្លាក់ចុះនៃសេដ្ឋកិច្ចនៅសហរដ្ឋអាមេរិក និងសហភាពអឺរ៉ុប និងការធ្លាក់ចុះសក្តានុពលនៃកំណើនសេដ្ឋកិច្ចរបស់ចិន និងការកើនឡើងអតិផរណាជាសកល ក្នុងចំណោមភាពមិនច្បាស់លាស់ផ្សេងទៀតអាចប៉ះពាល់ដល់ការស្តារឡើងវិញនៃសេដ្ឋកិច្ចរបស់ឥណ្ឌូនេស៊ី នៅក្នុងត្រីមាសទី៤ ឆ្នាំ ២០២១ និងនៅឆ្នាំក្រោយ។ ខណៈ រដ្ឋាភិបាលក៏កំពុងឃ្លាំមើលការប្រែប្រួលទីផ្សារហិរញ្ញវត្ថុ និងតម្រូវការទំនិញទាបពីទីផ្សារប្រទេសកំពុងរីកចម្រើនផងដែរ៕

*ដោយ ស៊ិន សុភារ៉ា*

*ប្រភព៖ គេហទំព័រសារព័ Channel News Asia ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២១*

## សេដ្ឋកិច្ចសកល

### ចក្រភពអង់គ្លេសនឹងដំឡើងប្រាក់ឈ្នួលអប្បបរមាដល់ ៩.៥០ ផោនក្នុងមួយម៉ោង



*ប្រភព៖ REUTERS/Phil Noble/File Photo*

ចក្រភពអង់គ្លេស នឹងប្រកាសការដំឡើងប្រាក់ឈ្នួលអប្បបរមារបស់ខ្លួនសម្រាប់អ្នកមានអាយុចាប់ពី ២៣ ឆ្នាំឡើងទៅ ដល់ ៩.៥០ ផោន (១៣.០៦ ដុល្លារ) ក្នុងមួយម៉ោង ពី ៨.៩១ ផោន នៅក្នុងសេចក្តីថ្លែងហេតុអំពីថវិកាជាតិ។

រដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ Rishi Sunak បានធ្វើសេចក្តីថ្លែងហេតុ មុនការធ្វើបទបង្ហាញអំពី ថវិកាប្រចាំឆ្នាំថា "ការបង្កើនប្រាក់ឈ្នួលនេះ ធានាថាយើងកំពុងធ្វើឱ្យប្រាក់ឈ្នួលការងារ និងធ្វើឱ្យយើងដើរលើផ្លូវ ដើម្បីបំពេញតាមគោលដៅរបស់យើងក្នុងការបញ្ចប់ប្រាក់ឈ្នួលទាបនៅចុងអណ្តត្តិរបស់សភានាពេលនេះ" ។

ជាមួយគ្នានេះ ការដំឡើងប្រាក់ឈ្នួលអប្បបរមានេះនឹងចូលជាធរមាន នៅខែមេសា ឆ្នាំ២០២២។ អត្រាសម្រាប់មនុស្សដែលមានអាយុក្រោម ២៣ ឆ្នាំ ដែលត្រូវបានទទួលប្រាក់ឈ្នួលអប្បបរមាទាបក៏កើនឡើងផងដែរ។*ដោយ វត្តា វង្សវឌ្ឍនៈ*

*ប្រភព៖ គេហទំព័រសារព័ត៌មានReutersចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២១*

### ព្រឹទ្ធសភាគណបក្សប្រជាធិបតេយ្យជំរុញឱ្យយកពន្ធលើមហាសេដ្ឋី ដើម្បីជួយផ្តល់មូលនិធិដល់ផែនការចំណាយ



*ប្រភព៖ Tom Williams | Pool | Reuters*

សមាជិកព្រឹទ្ធសភាគណបក្សប្រជាធិបតេយ្យ កំពុងសម្លឹងមើលការយកពន្ធលើមហាសេដ្ឋីធំ ដោយបង្កើនពន្ធលើលើប្រាក់ចំណូល និងការដំឡើងពន្ធសាជីវកម្ម នៅពេលដែលគណបក្សប្រជាធិបតេយ្យជិតឈានទៅដល់ការបញ្ចប់ការរៀបចំកញ្ចប់ចំណាយសង្គម។

នៅក្នុងសំណើ ដែលហៅថា ពន្ធលើប្រាក់ចំណូលរបស់មហាសេដ្ឋី អាចប៉ះពាល់ដល់ជនជាតិអាមេរិកប្រហែល ៧០០ នាក់ ដែលមានទ្រព្យសម្បត្តិ ១ ប៊ីលានដុល្លារ ឬរកប្រាក់ចំណូលបាន ១០០ លានដុល្លារក្នុងមួយឆ្នាំ សម្រាប់រយៈពេល ០៣ ឆ្នាំជាប់ៗគ្នា។

ជាមួយគ្នានេះ មហាសេដ្ឋី អាចប្រឈមមុខនឹងការយកពន្ធប្រចាំឆ្នាំ លើការកើនឡើងនៃទ្រព្យសកម្ម ដូចជាភាគហ៊ុន និងសញ្ញាប័ណ្ណ ដោយមិនគិតពីពេលដែលពួកគេលក់ ឬហៅថាប្រព័ន្ធនៃតម្លៃទ្រព្យសកម្មដោយតម្លៃទីផ្សារថ្មីៗបំផុត "mark-to-market" ។ ទោះជាយ៉ាងណាក៏ដោយ វិនិយោគិននៅតែអាចផាត់ទាត់បំណុលខាតបង់ជារៀងរាល់ឆ្នាំ។ ទន្ទឹមនឹងនេះ ផែនការនេះ ក៏បានលើកឡើងអំពីកំណើនសម្រាប់ទ្រព្យសម្បត្តិដែលមិនអាចជួញដូរបានរបស់អ្នកមាន ដូចជា អចលនទ្រព្យ រួមទាំងការបង់ថ្លៃសម្រាប់ប្រាក់ចំណេញដែលគេចពីការបង់ពន្ធបច្ចុប្បន្ន ហើយត្រូវបានពន្យារពេលរហូតដល់ថ្ងៃក្រោយនៅលើការលក់។

ជនជាតិអាមេរិកភាគច្រើនរកប្រាក់ចិញ្ចឹមជីវិតតាមរយៈប្រាក់ឈ្នួល ចំណែកឯអ្នកមានបំផុតអាចទទួលបានប្រាក់ចំណូលតាមរយៈការប្រាក់ ភាគលាភ ការកើនឡើងមូលធន ឬការជួលពីការវិនិយោគ ដែលគេស្គាល់ថាជាចំណូលមូលធន។

*ដោយ វត្ថា វង្សវឌ្ឍនៈ*

*ប្រភព៖ គេហទំព័រសារព័ត៌មាន CNBC ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០២១*

## អាមេរិកអនុញ្ញាតឲ្យលក់ផលិតផលតម្លៃរាប់ពាន់លានដុល្លារ ទៅឲ្យឱ្យក្រុមហ៊ុនចិន Huawei និងSMIC




*ដោយ ខេមបូណ្ឌមីស*

ក្រុមហ៊ុនរបស់អាមេរិកជាច្រើនបានទទួលអាជ្ញាបណ្ណពីការលក់ទំនិញ និងបច្ចេកវិទ្យារបស់ពួកគេទៅឱ្យក្រុមហ៊ុនទូរគមនាគមន៍យក្សចិន Huawei និងក្រុមហ៊ុនផលិតបន្ទះឈីប ស្មាយ (SMIC) របស់ចិន ទោះបីជាក្រុមហ៊ុនចិនទាំងពីរនេះស្ថិតក្នុងបញ្ជីខ្មៅរបស់សហរដ្ឋអាមេរិកក៏ដោយ។ អាជ្ញាបណ្ណនាំចេញចំនួន ១១៣ ដែលមានតម្លៃ ៦១ ពាន់លានដុល្លារត្រូវបានអនុម័តសម្រាប់អ្នកផ្គត់ផ្គង់អាមេរិក ដើម្បីដឹកជញ្ជូនផលិតផលទៅកាន់ក្រុមហ៊ុន Huawei ខណៈដែលអាជ្ញាប័ណ្ណចំនួន ១៨៨ ផ្សេងទៀត មានតម្លៃជិត ៤២ ពាន់លានដុល្លារត្រូវបានទទួលភ្លើងខៀវសម្រាប់ក្រុមហ៊ុនស្មាយ (SMIC)របស់ចិនផងដែរ។

កន្លងមកទីក្រុងវ៉ាស៊ីនតោនបានតាមសង្កត់ក្រុមហ៊ុនចិនក្នុងការប្រើប្រាស់បច្ចេកវិទ្យាទំនើបរបស់អាមេរិក ហើយបានដាក់ក្រុមហ៊ុនចិនជាច្រើនចូលក្នុងបញ្ជីខ្មៅរបស់អាមេរិក។ ក្រុមហ៊ុន Huawei ត្រូវបានដាក់ក្នុងបញ្ជីខ្មៅពាណិជ្ជកម្មតាំងពីខែឧសភា ឆ្នាំ ២០១៩មកម្ល៉េះ ដោយអាមេរិកចោទប្រកាន់ក្រុមហ៊ុនចិនមួយនេះថាមានការគំរាមកំហែងដល់បញ្ហាសន្តិសុខជាតិរបស់អាមេរិក និងបានបង្ខំឱ្យអ្នកផ្គត់ផ្គង់របស់សហរដ្ឋអាមេរិក និងក្រុមហ៊ុនផ្សេងទៀត មិនឱ្យវិនិយោគជាមួយក្រុមហ៊ុននេះ លើកលែងតែទទួលបានអាជ្ញាបណ្ណពិសេសពីរដ្ឋាភិបាលអាមេរិក។ ក្រុមហ៊ុនចិនដ៏ធំមួយទៀត គឺស្មាយ (SMIC) ត្រូវបានបញ្ចូលទៅក្នុងបញ្ជីខ្មៅនៅក្នុងខែធ្នូ ឆ្នាំ ២០២០ ដោយអាមេរិកចោទថាបានបង្វែរបច្ចេកវិទ្យាទំនើបទៅឱ្យយោធាចិន។

ការដែលអាមេរិកបើកផ្លូវឱ្យក្រុមហ៊ុនរបស់ខ្លួនអាចផ្គត់ផ្គង់ផលិតផល និងបច្ចេកវិទ្យាទៅឱ្យក្រុមហ៊ុនចិននាពេលនេះ គឺអាចជាសញ្ញាល្អបន្តិចឡើងវិញនៅក្នុងការឈានទៅបើកការចរចាពាណិជ្ជកម្មរវាងចិន និងអាមេរិក ដែលបានជាប់គាំងមកអស់រយៈពេលយូរខែឆ្នាំមកហើយនោះ។

គណបក្សសាធារណរដ្ឋរបស់សហរដ្ឋអាមេរិកមិនពេញចិត្តចំពោះការលក់ទំនិញ និងបច្ចេកវិទ្យាឱ្យទៅក្រុមហ៊ុនចិន ដែលមានក្នុងបញ្ជីខ្មៅរបស់ខ្លួននោះឡើយ ព្រោះគួរគិតគូរពីការគំរាមកំហែងផ្នែកសេដ្ឋកិច្ច និងសន្តិសុខ ដែលអាចកើតមានឡើងដោយគណបក្សកុម្មុយនីស្តចិននេះ៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព៖ខេមបូឌាមីសចេញផ្សាយថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២១។*

**កំណើនសេដ្ឋកិច្ចយឺតជំរុញចិនឱ្យពន្លឿនការបោះផ្សាយមូលបត្ររដ្ឋក្នុងស្រុក ២២៤ ពាន់លានដុល្លារបន្ថែម**



*ដោយ ខេមបូឌាមីស (រូបតំណាង ការពន្លឿនការបោះផ្សាយមូលបត្ររដ្ឋរបស់ចិន)*

ប្រទេសចិនមានបំណងនឹងពន្លឿនការចេញបោះផ្សាយលក់មូលបត្របំណុលក្នុងស្រុកបន្ថែម ដើម្បីគាំទ្រដល់ការស្ទុះងើបឡើងវិញនៃកំណើនសេដ្ឋកិច្ចចិន បន្ទាប់ពីមានកំណើនសេដ្ឋកិច្ចថយចុះខ្លាំងនៅត្រីមាសទី៣ឆ្នាំ ២០២១ ដែលជាកំណើនមួយយឺតបំផុតនៅក្នុងឆ្នាំនេះ ដោយសារតែបញ្ហាកង្វះខាតថាមពល និងភាពប្របូកប្របល់នៅក្នុងវិស័យអចលនទ្រព្យនៅក្នុងប្រទេស។

រដ្ឋាភិបាលចិន បានកំណត់កូតាបោះផ្សាយមូលបត្របំណុលរដ្ឋពិសេសរបស់ខ្លួនក្នុងតម្លៃសរុបជាង ៥៧០ ពាន់លានដុល្លារអាមេរិក ដែលភាគច្រើនផ្តល់មូលនិធិដល់គម្រោងហេដ្ឋារចនាសម្ព័ន្ធ។ ៩ខែឆ្នាំនេះ ចិនបានបោះផ្សាយមូលបត្របំណុលរដ្ឋបានជិត៣៥០ពាន់លានដុល្លារអាមេរិកហើយ នៅសល់ប្រមាណជាង ២២៤ពាន់លានដុល្លារអាមេរិកទៀត ដែលរដ្ឋាភិបាលចិនត្រូវបន្តពន្លឿន គឺមានការធ្វើឡើងយ៉ាងលឿនតាំងពីខែសីហាមកម្ល៉េះ ធ្វើយ៉ាងណាសម្រេចឱ្យបានគ្រប់កូតាបោះផ្សាយមូលបត្របំណុលនៅឆ្នាំ២០២១នេះ នៅត្រឹមចុងខែវិច្ឆិកាខាងមុខ ដើម្បីយកបំណុលរដ្ឋពិសេសនេះ ទៅអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម។

ប្រហែលពាក់កណ្តាលនៃមូលនិធិ ដែលប្រមូលបានពីការបោះផ្សាយមូលបត្រពិសេសរបស់រដ្ឋ ក្នុងអំឡុងខែមករាដល់ខែកញ្ញាកន្លងទៅនេះ ត្រូវបានយកទៅអភិវឌ្ឍន៍វិស័យដឹកជញ្ជូន ហេដ្ឋារចនាសម្ព័ន្ធទីក្រុង និង

ឧស្សាហកម្មអចលនទ្រព្យ និងមូលនិធិនៅសល់ផ្សេងទៀតគឺប្រើទៅលើការអភិវឌ្ឍគម្រោងលំនៅដ្ឋានតម្លៃសមរម្យ វិស័យអប់រំ និងការថែទាំសុខភាពពលរដ្ឋជាដើម។ បើមើលទៅលើចំណូលសារពើពន្ធរបស់ចិនវិញនៅ៩ខែដំបូងឆ្នាំ២០២១ បានកើនឡើងជាង១៦% ធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន ខណៈដែលចំណាយសារពើពន្ធវិញ ក៏បានកើនឡើង ២,៣%។ បើតាមការព្យាករថ្មីចុងក្រោយមួយពីអង្គការមូលនិធិរូបិយវត្ថុអន្តរជាតិ IMF កំណើនសេដ្ឋកិច្ចចិននឹងកើនឡើងត្រឹម ៨% គឺទាបជាងអ្វីដែលបានព្យាករកាលពីខែកក្កដាកន្លងទៅ ដែលថានឹងកើនដល់ ៨,១%៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព៖ខេមបូណូមីសចេញផ្សាយថ្ងៃទី២៦ខែតុលា ឆ្នាំ២០២១។*

## ពូជស្រូវកូនកាត់របស់ចិនបំបែកកំណត់ត្រាថ្មី អាចផ្តល់ទិន្នផលបានជិត២៤តោន ក្នុង១ហិកតា



*ដោយ ខេមបូណូមីស*

មន្ទីពិសោធន៍ចិនបានដឹងថា ពូជស្រូវមួយប្រភេទដែលជនជាតិចិនបានបង្កាត់ អាចផ្តល់ទិន្នផលជិត២៤តោនក្នុងមួយហិកតា។ ស្រូវប្រភេទនេះ អាចធ្វើបាន២ដងក្នុងមួយឆ្នាំ ដោយរដូវទីមួយ អាចធ្វើឡើងចាប់ពីចុងខែឧសភាដល់ចុងខែកក្កដា និងមួយរដូវទៀតចាប់ផ្តើមពីចុងខែកក្កដាហើយប្រមូលផលនៅខែវិច្ឆិកា។ កសិករក៏អាចជ្រើសរើសយកការដាំដុះតែម្តងក្នុងមួយឆ្នាំក៏បានដោយអាចដាំបានចាប់ពីចុងខែមិថុនា និងប្រមូលផលនៅចុងខែតុលា។

មជ្ឈមណ្ឌលជាតិស្រាវជ្រាវ និងអភិវឌ្ឍន៍ស្រូវកូនកាត់របស់ចិន ហៅកាត់ថា មជ្ឈមណ្ឌលស្រាវជ្រាវស្រូវហ៊ូណាន បានចេញលទ្ធផលពីការដាំសាកល្បងដែលទទួលបានពីរដូវប្រមូលផលលើកទី១មានតែជិត១៤តោនក្នុងមួយហិកតា ហើយសរុបទិន្នផលទាំង២លើកនៅឆ្នាំដដែល សម្រេចបានជិត ២៤ តោនក្នុងមួយហិកតា។ ទិន្នផលនេះ បានបំបែកកំណត់ត្រាថ្មី ដោយក្លាយជាពូជស្រូវកូនកាត់ ដែលផ្តល់ទិន្នផលខ្ពស់បំផុតនៅលើពិភពលោក។

ប្រភេទស្រូវកូនកាត់របស់ប្រទេសចិនបានផ្គត់ផ្គង់ដល់ពលរដ្ឋ១/៥ និងប្រើប្រាស់ផ្ទៃដីដាំដុះតិចជាង ៩% នៃផ្ទៃដីសរុបរបស់ពិភពលោក។ ប្រភេទស្រូវកូនកាត់របស់ចិនក៏ត្រូវបានដាំដុះយ៉ាងទូលំទូលាយនៅក្នុងប្រទេស និងតំបន់ជាង៦០ក្រៅប្រទេសប្រមាណ៧លានហិកតា៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព ៖ ខេមបូណូមីស ចេញផ្សាយថ្ងៃទី២១ តុលា ឆ្នាំ២០២១។*

## ទិន្នន័យស្រាវជ្រាវសម្រាប់សប្តាហ៍បន្ទាប់

ថ្ងៃចន្ទ ទី០១ ខែវិច្ឆិកា ឆ្នាំ២០២១

- អតិរេកពាណិជ្ជកម្មរបស់កូរ៉េខាងត្បូងបានធ្លាក់ក្នុងខែកញ្ញា ឆ្នាំ 2021
- កំណើនអតិផរណាប្រចាំឆ្នាំរបស់ប្រទេសឥណ្ឌូនេស៊ី នៅក្នុងខែកញ្ញា ឆ្នាំ 2021

ថ្ងៃអង្គារ ទី០២ ខែវិច្ឆិកា ឆ្នាំ២០២១

- អតិរេកពាណិជ្ជកម្មរបស់ប្រទេសប្រេស៊ីលបានរួមតូច ក្នុងខែកញ្ញា ឆ្នាំ 2021

- ឱនភាពពាណិជ្ជកម្មរបស់ឥណ្ឌាត្រូវបានកែសម្រួល ក្នុងខែកញ្ញា ធៀបនឹងការប៉ាន់ប្រមាណបឋម

ថ្ងៃពុធ ទី០៣ ខែវិច្ឆិកា ឆ្នាំ២០២១

- កំណើនប្រាក់ចំណូលពន្ធអាហ្សង់ទីនបានកើនក្នុងខែកញ្ញា
- កំណើនសន្ទស្សន៍តម្លៃទំនិញប្រើប្រាស់នៅក្នុងប្រទេសទួរគី ក្នុងខែកញ្ញា ឆ្នាំ 2021

ថ្ងៃព្រហស្បតិ៍ ទី០៤ ខែវិច្ឆិកា ឆ្នាំ២០២១

- កំណើនការនាំចេញផលិតផល ក្នុងខែសីហា ឆ្នាំ 2021 ចំពេលមានតម្រូវការនៅក្រៅប្រទេសដ៏រឹងមាំ
- ការចុះបញ្ជីរថយន្តថ្មីនៅចក្រភពអង់គ្លេសបានធ្លាក់ចុះ ក្នុងខែកញ្ញា ឆ្នាំ 2021

ថ្ងៃសុក្រ ទី០៥ ខែវិច្ឆិកា ឆ្នាំ២០២១

- កំណើនសេដ្ឋកិច្ចរបស់ប្រទេសឥណ្ឌូនេស៊ី ក្នុងត្រីមាសទី 2 ឆ្នាំ 2021
- អត្រាគ្មានការងារធ្វើនៅសហរដ្ឋអាមេរិកបានធ្លាក់ នៅក្នុងខែកញ្ញា ឆ្នាំ 2021៕